**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា**

**សាលាបឋមសិក្សា FRANCIS SCOTT KEY**

**2230 SOUTH 8TH STREET**

**PHILADELPHIA, PA 19148**

**ទូរស័ព្ទ៖ (២១៥) ៩៥២-៦២១៦** **ទូរសារ៖ (២១៥) ៩៥២-៨៥០៥**

ខែសីហា ឆ្នាំ២០១៣

ជូនចំពោះ មាតាបិតា និង អាណាព្យាបាល៖

នាងខ្ញុំមានមោទនភាព និងមានការរំភើបចិត្ត យ៉ាងខ្លាំង នៅពេលដែលនាងខ្ញុំសរសេរលិខិតណែនាំខ្លួននេះជូនទៅលោកអ្នក ថានាងខ្ញុំគឺជានាយិកាដែលទើបនឹងតែងតាំងថ្មី របស់សាលាបឋមសិក្សា Francis Scott Key សម្រាប់ឆ្នាំសិក្សា២០១៣-២០១៤។ នាងខ្ញុំមានបទពិសោធន៍ផ្នែកអប់រំអស់រយៈពេលជាងដប់ប្រាំឆ្នាំមកហើយ ពីថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី១២ អាជីពរបស់ខ្ញុំផ្តោតទៅលើការអប់រំផ្នែក ពីរភាសា និង ESOL ជាមួយនឹងការអភិវឌ្ឍន៍របស់កុមារមុនថ្នាក់មេត្តយ្យ។ បទពិសោធន៍ផ្នែករដ្ឋបាលរបស់ខ្ញុំក្នុងពេលថ្មីៗនេះ គឺបានមកពីការធ្វើជានាយិកាសាលាបឋមសិក្សា Morrison ដែលជាសាលាថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៨ នៅហ្វីឡាខាងជើង អស់រយៈពេលបីឆ្នាំ។ មុនពេលនាងខ្ញុំធ្វើជានាយិកាសាលានៅហ្វីឡាដែលហ្វ្យា៉ នាងខ្ញុំបានធ្វើការនៅការិយាល័យផ្នែកភាសាចម្រុះ នៅការិយាល័យកណ្តាលនៃក្រសួងអប់រំ ក្រោយពីបានចំណាយពេល១១ឆ្នាំ ក្នុងប្រព័ន្ធអប់រំនៅរដ្ឋ តិចសាស។ នាងខ្ញុំរីករាយ នឹងនាំយកនូវចំណេះដឹងជាអ្នកដឹកនាំផ្នែកអប់រំរបស់នាងខ្ញុំ មកសាលារបស់កូនលោកអ្នក ព្រមទាំងសហការក្នុងការអប់រំជាមួយលោកអ្នក ដើម្បីធ្វើយ៉ាងណាឲ្យកូនលោកអ្នកបានទទួលជោគជ័យ។

ជាមួយបុគ្គលិករបស់យើង នាងខ្ញុំនឹងខំប្រឹងធ្វើការដើម្បីបន្តកេរ្តិ៍ដំណែលនៃជោគជ័យដែលសាលា Key ទទួលបាន ដោយធ្វើឲ្យមានទំនាក់ទំនងកាន់តែស្អិតល្មួត ជាមួយ មាតាបិតា សិស្សានុសិស្ស បុគ្គលិក និងដៃគូរបស់យើងនៅក្នុងសហគមន៍។ យើងនឹងផ្តោតទៅលើ គោលបំណងនៃការអប់រំ៖ ចំណេះដឹងនៃសតវត្សទី២១ បង្កើតបរិយាកាស ដែលមានសុវត្ថិភាព និងមានការអប់រំ សម្រាប់សិស្ស ប្រើទិន្នន័យដើម្បីផ្តល់ព័ត៌មានសម្រាប់ការបង្ហាត់បង្រៀន អនុវត្តខ្ជាប់ខ្ជួននូវវិធីសាស្ត្របង្ហាត់បង្រៀនដែលមានប្រសិទ្ធិភាព ដើម្បីជួយឲ្យយើងទទួលបានជោគជ័យតាមខ្នាតគំរូសំខាន់ៗរបស់រដ្ឋ និង ផ្តល់ឱកាសរៀនបន្ថែម ដែលគួរឲ្យរីករាយ និងឲ្យខិតខំឲ្យអស់ពីសមត្ថភាព សម្រាប់សិស្សានុសិស្សទាំងអស់។

នាងខ្ញុំសង្ឃឹមថានឹងទទួលបានជោគជ័យក្នុងឆ្នាំនេះ ដោយសារក្រុមរបស់ខ្ញុំ និងនាងខ្ញុំ គាំទ្រដល់ ការសិក្សា ការរីកចម្រើនផ្នែកទំនាក់ទំនងក្នុងសង្គម និងផ្លូវចិត្ត របស់កូនលោកអ្នក នៅសាលាបឋមសិក្សា Francis Scott Key។

ក្នុងឆ្នាំនេះ នាងខ្ញុំសង្ឃឹមថា យើងនឹងសហការគ្នាដើម្បីផ្តល់ឲ្យសិស្សានុសិស្សនៅសាលា Key នូវឱកាសដែលល្អបំផុតក្នុងការរៀបចំពួកគេឲ្យក្លាយជាពលរដ្ឋដ៏ល្អ ដើម្បីអាចដោះស្រាយបញ្ហាផ្សេងៗក្នុងសតវត្សទី២១ ដោយសារមូលដ្ឋានដ៏រឹងមាំដែលបានបង្កើតឡើងនៅសាលារបស់យើង។ ជានាយិកាសាលា នាងខ្ញុំរង់ចាំបើកទ្វារទទួលលោកអ្នកគ្រប់ពេលវេលា ហើយស្វាគមន៍នូវយោបល់របស់លោកអ្នក។ សូមមកជួប ឬទូរស័ព្ទមកធ្វើការណាត់ជួបដើម្បីពិភាក្សាអំពី ការព្រួយបារម្ភ យោបល់ ឬគំនិត អ្វីមួយ ដើម្បីជួយធ្វើឲ្យឆ្នាំនេះទៅជាឆ្នាំដ៏ល្អបំផុត!

ជាការរំលឹកឡើងវិញ ថ្ងៃចូលរៀនដំបូងសម្រាប់សិស្សានុសិស្សថ្នាក់ទី១ ដល់ទី៦ គឺនៅថ្ងៃច័ន្ទ ទី៩ ខែកញ្ញា ឆ្នាំ២០១៣។ ថ្ងៃចូលរៀនដំបូងសម្រាប់សិស្សានុសិស្សថ្នាក់មត្តេយ្យ គឺនៅថ្ងៃច័ន្ទ ទី១៦ ខែកញ្ញា ឆ្នាំ២០១៣។ នាងខ្ញុំរង់ចាំសហការជាមួយលោកអ្នក និងកូនរបស់លោកអ្នក។

ដោយការសហការគ្នា

***Ms. Stephanie Stover***